ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល                    ជាតិ        សាសនា    ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី

លេខ: ១៤៣

ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០១

តាងនាមប្រជារាស្ត្រខ្មែរ

សាលដីកា

តុលាការកំពូល

លេខ: ១៣៥

ចុះថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០២

បានបើកសវនាការជំនុំជំរះ ជាសាធារណៈនៅថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០២ ដោយមានសមាសភាពដូចតទៅ :

១- ឯកឧត្តម ឌិត មុន្ទី ជាប្រធាន

២- លោក វេង្យល ម្ជូន ជាចៅក្រម

៣- លោក គង់ ភីរុន ជាចៅក្រម

៤- លោក ឃឹម ស៊ីផល ជាចៅក្រម

៥- លោក សោម សិរីវុឌ្ឍជាចៅក្រមរបាយការណ៍

ក្រឡាបញ្ជី

អ្នកស្រី ភួង ចន្ថា

តំណាងមហាអយ្យការ

ឯកឧត្តម ដួន ស៊ុនទៀង ជាអគ្គព្រះរាជអាជ្ញារង

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ ៣៧ " ឃ " ចុះថ្ងៃទី២៨ ខែ មិនា ឆ្នាំ ២០០១ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៦៩៤ ចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០០ របស់សាលាឧទ្ធរណ៍ ។

- រវាងដើមចោទឈ្មោះ ប្រេង ស្រីទួច " ជាម្ចាស់បណ្តឹងសាទុក្ខ " ភេទស្រី អាយុ ៣៣ ឆ្នាំ ជាតិខ្មែរ មុខរបរ បើកផ្ទះសំណាក់ មានទីលំនៅសព្វថ្ងៃភូមិច្បាលិលេឃ្យ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។ ឪពុកឈ្មោះ ប្រេង គិចដួន " ស "

ម្តាយឈ្មោះខ្វៃ ទីណៅ "ស" ប្តីឈ្មោះ ចាន់ ស្រស់ មានកូន ០១ នាក់ ។

- និងចុងចម្លើយឈ្មោះ សៅ សុគន្ធី "ជាចុងបណ្តឹងសាទុក្ខ" ភេទប្រុស អាយុ ៣២ ឆ្នាំ ជាតិខ្មែរ មុខរបរ យោធិនសហអគ្គបញ្ជាការប្រចាំតំបន់ប៉ោយប៉ែត មានទីលំនៅសព្វថ្ងៃ ភូមិប៉ូលិសលេខ១ ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ។ ឪពុកឈ្មោះសៅ សុគន្ធ "រស់" ម្តាយឈ្មោះ ស្រី ពៅ "រស់" ។

ផ្ទេរសិទ្ធិអោយឈ្មោះ តុប សារុន ភេទប្រុស អាយុ ៥២ ឆ្នាំ ជាតិខ្មែរ មុខរបរ លក់ដូរ មានទីលំនៅសព្វថ្ងៃភូមិ ២០ ឧសភា ឃុំស្វាយប៉ោ ស្រុកស្វាយប៉ោ ខេត្តបាត់ដំបង ។

មានមេធាវី លោក ទួត លុច

កម្មវត្ថុ : ប្តឹងសុំគ្រប់គ្រងផ្ទះល្វែងលេខ ២៣៨បេ៊ និង ដី

បានឃើញបណ្តឹងសាទុក្ខលេខ ១០១ ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ២០០១ របស់ឈ្មោះ ស្រេង ស្រីទូច ប្តឹងមិនសុខចិត្តនិងសេចក្តីសំរេចនៃសាលដីកាលេខ ៣៣ "ឈ" ចុះថ្ងៃទី ២៩ ខែ មិនា ឆ្នាំ ២០០១ របស់សាលាឧទ្ធរណ៍ទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១៤៣ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ-២០០១ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី ១១.០២.៩៩ របស់ឈ្មោះស្រេង ស្រីទូច ប្តឹងទាម-ទារដីនិងផ្ទះលេខ ៣៣៨ ពីឈ្មោះសៅ សុគន្ធី ដោយអះអាងហេតុថា ខ្លួនបានគ្រប់គ្រងផ្ទះល្វែងលេខ៣៣៨ ស្ថិតនៅផ្សារប៉ោយប៉ែត តាំងពីឆ្នាំ១៩៨១ រហូតមកដល់សព្វថ្ងៃនេះ លោក ស៊ុំ ឈំកាង ជាអ្នកប្រគល់អោយខ្លួន ហើយទើបតែមកដល់ថ្ងៃទី០៩.០២.៩៩ នេះក៏មានចុងចម្លើយឈ្មោះសៅ សុគន្ធី មកអះអាងថា ជាផ្ទះរបស់គាត់ទៅវិញ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ៦៥ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ១៩៩៩ របស់តុលាការខេត្តបន្ទាយមានជ័យ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១- ទទួលពាក្យបណ្តឹងចុះថ្ងៃទី ១១.០២.៩៩ របស់ដើមចោទឈ្មោះស្រេង ស្រីទូច ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២- បដិសេធសេចក្តីសំរេចលេខ ១៨ ដ.ណ.រ ចុះថ្ងៃទី២៣.០៣.៩៧ របស់សាលា-ខេត្តបន្ទាយមានជ័យ ចោលជាអសារបង់ ដោយទាស់ខុសនិងគតិច្បាប់ ។

៣- ទុកជាមោឃៈលិខិតផ្ទេរសិទ្ធិកាន់កាប់ផ្ទះល្វែងចុះថ្ងៃទី០៥.០២.៩៥ ពីលោក ផង់ ប្រសើដ្ឋ និងលោក លេ ឆាំរុង ដែលបានប្រគល់សិទ្ធិកាន់កាប់ផ្ទះល្វែងលេខ ៣៧៨ អោយចុងចម្លើយឈ្មោះ សៅ សុគន្ធី ចាប់ពីថ្ងៃនេះតទៅ ។

៤- ប្រគល់ដីនិងផ្ទះល្វែងលេខ៣៧៨ នៅផ្សារដេប៉ូប៉ិត ដែលដើមចោទ បាននិងកំពុងរស់នៅ និងកាន់កាប់តាំងពីឆ្នាំ១៩៨១ រហូតមកដល់សព្វថ្ងៃអោយទៅដើមចោទឈ្មោះស្រេង ស្រីទូច និងលោក ចាន់ ស្រស់ កាន់កាប់ជាកម្មសិទ្ធិចាប់ពីថ្ងៃនេះតទៅ ។

៥- បង្គាប់អោយចុងចម្លើយឈ្មោះ សៅ សុគន្ធី សងប្រាក់ប្រដាប់ក្តីចំនួន ៧.០០០ - រៀល ដែលដើមចោទ បានបង់ទុករួចហើយអោយទៅដើមចោទវិញ និងបង្គាប់អោយចុងចម្លើយឈ្មោះ - សៅ សុគន្ធី បង់ពន្ធសមាមាត្រមួយភាគរយ លើតំលៃដីនិងផ្ទះល្វែងលេខ៣៧៨ ដែលត្រូវប្រគល់អោយដើម-ចោទ ស្មើនឹង ១.៤០០បាត ដើម្បីបង់ចូលថវិការដ្ឋ ប៉ែតសិបភាគរយស្មើនឹង ១.១២០បាត និងដើម្បីបង់ចូលហិបប្រាក់ក្រឡាបញ្ជីទូទាំងប្រទេស ម្ភៃភាគរយស្មើនឹង ២៨០បាត ។

តាមមាត្រា ២, ៣, ១៧, និង ១៨ នៃច្បាប់ភូមិបាល ។

សាលក្រមនេះជំនុំជំរះជាសាធារណៈចំពោះមុខ ដើមចោទឈ្មោះស្រេង ស្រីទូច កំបាំងមុខចុងចម្លើយឈ្មោះ សៅ សុគន្ធី ហើយទុកសិទ្ធិអោយប្តឹងទាស់ក្នុងរយៈពេល១៥ថ្ងៃ គិតចាប់ពីថ្ងៃទទួលសាលក្រមកំបាំងមុខ និងបើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ គិតចាប់តាំងពីថ្ងៃ ផុតបណ្តឹងជំទាស់តទៅ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៣៤ ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ១៩៩៥ របស់ឈ្មោះ គុប សារុន ប្តឹងមិនសុខចិត្តនឹងសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៣៧ "ឃ" ចុះថ្ងៃទី ២៥ ខែ មិនា ឆ្នាំ ២០០១ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១- ទទួលបណ្តឹងឧទ្ធរណ៍លេខ ៣៤ ចុះថ្ងៃទី ១២ - កក្កដា ១៩៩៥ របស់ឈ្មោះ - គុប សារុន តំណាងអោយឈ្មោះ សៅ សុគន្ធី ជាចុងចម្លើយ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២- បដិសេធសាលក្រមរដ្ឋប្បវេណីលេខ ៦៥ ចុះថ្ងៃទី២២.៦.៩៥ របស់តុលាការខេត្តបន្ទាយមានជ័យ ចោលជាអសារបង់ ។

៣- ប្រគល់ផ្ទះល្វែងលេខ ៣៧៨ អោយទៅចុងចម្លើយឈ្មោះ សៅ សុគន្ធី ដែលមាន

តំណាងឈ្មោះ តុប សារុន តាមដីកាសំរេចលេខ ១៨ ដែលចុះថ្ងៃទី២៦.៦.៩៧ របស់សាលាខេត្តបន្ទាយមានជ័យ និងតាមលិខិតផ្ទេរសិទ្ធិកាន់កាប់ផ្ទះចុះថ្ងៃទី ០៥ កុម្ភៈ ១៩៩៥ ។

៤- បង្គាប់អោយដើមចោទឈ្មោះ ស្រេង ស្រីទូច រើសសំភារៈប្រើប្រាស់ក្នុងគ្រួសារ ព្រមទាំងក្រុមគ្រួសារចុះចេញពីផ្ទះកើតហេតុ ចាប់ពីក្រោយពេលសាលដីកានេះមានអានុភាពអនុវត្ត ។

៥- រឹបអូសប្រាក់ប្រដាប់ក្តី ដែលដើមបណ្តឹងឧទ្ធរណ៍ឈ្មោះ សៅ សុគន្ធី បានបង់រួចហើយ គឺ ពន្ធប្តឹង និងពន្ធចុះបញ្ជីក្តី ២៥៥០រៀល រង្វាន់ក្រឡាបញ្ជីការពីប្រាក់៤៥០រៀល ចំណាយលើកិច្ចប្រគល់ដីកាកោះ ៥.០០០រៀល និងចំណាយលើអាជ្ញាធរតុលាការ ៥.០០០រៀល សរុប ១៣.០០០រៀល។

- កាលបើផុតកំណត់ប្តឹងសាទុក្ខ បង្គាប់អោយដើមចោទឈ្មោះ ស្រេង ស្រីទូច សងប្រាក់ ១៣.០០០រៀលនេះ ទៅឈ្មោះសៅ សុគន្ធី វិញ និងអោយបង់ពន្ធសមាមាត្រ ១.៥០០ បាត ដែលប្រាក់ពន្ធនេះ ៨០ភាគរយបានជាប្រយោជន៍ថវិការដ្ឋ និង ២០ភាគរយត្រូវបានជាប្រយោជន៍ក្រឡាបញ្ជីទូទាំងប្រទេស ។

៦ សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខគូក្តី បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ ១០១ ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០១ របស់ឈ្មោះ ស្រេង ស្រីទូច ប្តឹងមិនសុខចិត្ត និងសាលដីការបស់សាលាឧទ្ធរណ៍ទាំងមូល ធ្វើឡើងក្នុងកំណត់ច្បាប់។

បានឃើញសារណាការពារចុះថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០០១ របស់ឈ្មោះ ស្រេង ស្រីទូច ជាម្ចាស់បណ្តឹងសាទុក្ខ ។

បានឃើញសារណាតបចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០១ របស់ឈ្មោះ តុប សារុន ជាតំណាងអោយឈ្មោះសៅ សុគន្ធី ជាចុងបណ្តឹងសាទុក្ខ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា៖

- បណ្តឹងសាទុក្ខរបស់អ្នកស្រី ស្រេង ស្រីទូច ជាដើមចោទស្ថិតនៅក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិនិត្យពិចារណា ។

- សាលាឧទ្ធរណ៍មានការភ័ន្តច្រឡំ ដោយពុំបានពិចារណាទៅលិខិតអោយដំណឹងពីសាលាក្រុមកំពាំងមុខ ដែលបានជូនដំណឹងដល់ចុងចម្លើយសៅ សុគន្ធី ដែលកំពាំងមុខ ដោយបានបិទនៅលំនៅដ្ឋានរបស់ -

សៅ សុគន្ធី ហើយត្រូវបានលោកចៅក្រមជំនុំជំរះ ចារថាសាលក្រមនេះបានចូលជាស្ថាពរ ដោយសាមីខ្លួនពុំបានចូលប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

- នៅក្នុងឈុំរឿងមានលិខិតផ្ទេរសិទ្ធិរបស់លោកសៅ សុគន្ធី អោយលោក តុប សានុន ក្នុងការដោះស្រាយរឿងក្តីផ្ទះល្វែងលេខ៣៧៨ ប៉ុន្តែក្នុងពាក្យបណ្តឹងរបស់អ្នកស្រីស្រេង ស្រីទូច និងប្រជាជនពីនាក់ទៀតទៅសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១ និងសម្តេចនាយករដ្ឋមន្ត្រីទី២ ដាក់ថាអ្នកស្រីស្រេង ស្រីទូច ភេទស្រី អាយុ ៣១ ឆ្នាំ ផ្ទះលេខ៣៧៧ "ឯកសារ៥/៣" រីឯក្នុងពាក្យបណ្តឹងផ្ទាល់របស់អ្នកស្រី ស្រេង ស្រីទូច ខ្លួនឯងផ្ទាល់ដាក់ថាប្តឹងទាមទារផ្ទះល្វែងលេខ៣៧៨ ពីឈ្មោះសៅ សុគន្ធី ដូច្នេះគឺមានភាពមិនពុំច្បាស់លាស់អំពីលេខផ្ទះទំនាស់ពិតប្រាកដ ។

- ប្រជាជនទាំង៨គ្រួសារបានប្តឹងទៅសហនាយករដ្ឋមន្ត្រី សហនាយករដ្ឋមន្ត្រី បានជំរាបមកសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចុះធ្វើការដោះស្រាយផ្តល់មុខអោយរាជរដ្ឋាភិបាល ប៉ុន្តែពុំទាន់ឃើញមានការចូលរួមដោះស្រាយរបស់ក្រសួងមហាផ្ទៃ យ៉ាងណាទៅទៀតទេក្នុងរឿងនេះ ។

- សាលាឧទ្ធរណ៍ បានសំរេចសេចក្តីមកតាមតែការសំរេចរបស់ថ្នាក់ខេត្តបន្ទាយមានជ័យកន្លងមកទេ ដោយពុំចាំទាន់មានការចូលរួមដោះស្រាយរបស់ក្រសួងមហាផ្ទៃ និង គណៈរដ្ឋមន្ត្រីនៅឡើយ ដែលធ្វើអោយសេចក្តីសំរេចមិនទាន់មានមូលដ្ឋានរឹងមាំ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះមេត្តាពិនិត្យ និងសំរេចតាមច្បាប់តទៅ ។

បានស្តាប់ចម្លើយរបស់ឈ្មោះស្រេង ស្រីទូច ជាដើមចោទ និងជាម្ចាស់បណ្តឹង-សាទុក្ខនៅពេលជំនុំជំរះបានឆ្លើយថា បានជាខ្លួនប្តឹងសាទុក្ខមកតុលាការកំពូលនេះ មកពីសាលាឧទ្ធរណ៍សំរេចសេចក្តីមិនត្រឹមត្រូវអោយខ្លួន ព្រោះក្នុងរឿងក្តីនេះ សាលក្រមរបស់តុលាការខេត្តបន្ទាយមានជ័យបានចូលជាស្ថាពរហើយ ព្រោះថាភាគីខាងសៅ សុគន្ធី ពុំបានប្តឹងឧទ្ធរណ៍មកសាលាឧទ្ធរណ៍ទេ ។ ហើយដើមឡើយផ្ទះទំនាស់នេះស្ថិតនៅក្នុងការគ្រប់គ្រងរបស់គណៈកម្មាការប្រចាំសេដ្ឋកិច្ចតំបន់ប៉ោយប៉ែត ដែលមានលោកស៊ុំ ឈិណាង ជាប្រធានក្តាប់រួមនៅទីនោះ ។ ក្នុងនោះដែរប្តីខ្លួនជាកូនចៅរបស់លោក ស៊ុំ ឈិណាង ដោយគាត់មើលឃើញពីភាពខ្វះខាតគ្មានផ្ទះនៅ ទើបគាត់សំរេចប្រគល់ផ្ទះល្វែង១ល្វែងដែលមានលេខ៣៧៨នេះមកអោយគ្រួសារខ្លួនរស់នៅនៅឆ្នាំ១៩៩១ រហូតដល់សព្វថ្ងៃនេះដោយសុខសាន្ត ។ ហេតុដូច្នេះសុំលោកប្រធានតុលា-ការកំពូល មេត្តាជួយរកយុត្តិធម៌អោយខ្លួន ។

-ក្រោយបញ្ចប់អានសារណារបស់លោក គុយ សារុន " ជាចុងបណ្តឹងសាទុក្ខ "

បានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី ទួត លុច ការពារអោយចុងចម្លើយបានលើកឡើងបញ្ជាក់នៅពេលជំនុំជំរះនេះថា ចំពោះរឿងក្តីនេះ ខ្លួនសូមជំរាបថាកូនក្តីខ្លួនពុំបានទទួលដំណឹងពីសាលាក្រមកំពាំងមុខរបស់តុលាការខេត្តបន្ទាយមានជ័យឡើយ ។ ខ្លួនសូមបញ្ជាក់ថា លោក ម៉ម ម៉ឺន គាត់ដឹងថាលោក សៅ សុគន្ធី ជាប់គុកពីបទព្រហ្មទណ្ឌ. ហេតុអ្វីបានជាលោក ម៉ម ម៉ឺន មិនយកលិខិតជូនដំណឹងពីសាលាក្រមកំពាំងមុខអោយលោក សៅ សុគន្ធី នៅក្នុងគុកទៅ ។ ហើយបញ្ហាផ្ទះចំនាស់នេះគឺវាទាក់ទងរវាងខេត្ត និងលោក សៀង ណៅ លោក ផង់ ប្រសើផ្ទ បានលក់ផ្ទះចំនាស់នេះអោយលោក សៅ សុគន្ធី ដោយមានឯកសារត្រឹមត្រូវ ។ ចំណែកនាង ស្រេង ស្រីទូច ចូលមករស់នៅផ្ទះចំនាស់នេះដោយភាពអាណាធិបតេយ្យហើយត្រូវបានអាជ្ញាធរមានសមត្ថកិច្ចបណ្តេញជាច្រើនលើកច្រើនសារ តែឈ្មោះនេះនៅតែរឹងរូសមិនព្រមចេញសំអាងលើលោក ស៊ុំ ឈាង ជាអ្នកប្រគល់ផ្ទះអោយទៅវិញ ។ សុំឯកឧត្តមប្រធានមេត្តាតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយរបស់អ្នកស្រីស្រេង ស្រីទូច សារណារបស់លោក គុយ សារុន និងសេចក្តីសន្និដ្ឋានរបស់មេធាវីចុងចម្លើយ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ១០១ ចុះថ្ងៃទី០២.០៤.០១ របស់អ្នកស្រី ស្រេង ស្រេង ស្រីទូច ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបាន ដោយយោងតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ។

- យល់ឃើញថា ក្នុងបណ្តឹងសាទុក្ខលើកទី១ តុលាការកំពូល ពិចារណាតែអង្គច្បាប់ទេ ហើយបើសាលក្រមលេខ ៦៥ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៩ មានលក្ខណៈស្ថាពរហើយ ដោយ

មានចំណារពីចៅក្រមជំរះនិងក្រឡាបញ្ជីសវនាការរួចហើយ ដូច្នេះការដែលសាលាឧទ្ធរណ៍លើកយករឿងក្ដីនេះមកវិនិច្ឆ័យគឺជាការភ័ន្តច្រឡំ ។

- យល់ឃើញថា លោក គុប សារុន បានធ្វើសារណាការពាររឿងក្ដីរបស់លោកជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែពុំបានមកចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះ កំបាំងមុខលោក ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៣៧ " ឃ " ចុះថ្ងៃទី២៨.០៣.០១ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្ដីមកនេះមានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

វិនិច្ឆ័យសេចក្ដីចំពោះមុខអ្នកស្រី ស្រេង ស្រីទូច កំបាំងមុខលោក គុប សារុន ប៉ុន្តែចាត់ទុកជាចំពោះមុខ

១-ទទួលបណ្ដឹងសាទុក្ខលេខ ១០១ ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០១ របស់អ្នកស្រី ស្រេង ស្រីទូច ទុកជាត្រឹមត្រូវទាំងទំរង់ ទាំងគតិច្បាប់ ។

២- ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ៣៧ ចុះថ្ងៃទី ២៨ ខែ មិនា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ទាំងមូល ដោយឥតបង្វិល ។

៣- បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខ ១៤៣ ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០១ របស់តុលាការកំពូល ទៅតុលាការខេត្តបន្ទាយមានជ័យ ដើម្បីចាត់ការតាមច្បាប់ ។

៤- រឹបអូសប្រាក់ប្រដាប់ក្ដីចំនួន ១៩.០០០រៀល ដែលអ្នកស្រី ស្រេង ស្រីទូច បានបង់នៅតុលាការកំពូលគឺ :

- ពន្ធចុះបញ្ជីក្ដី និង ពន្ធហ៊ឹងចំនួន ៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់។

- ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ១៥.០០០រៀល សរុប ១៩.០០០រៀល ហើយតំរូវអោយលោក គុប សារុន សងប្រាក់ ១៩.០០០រៀល នេះទៅអ្នកស្រី ស្រេង ស្រីទូច វិញ ។

៥- សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី ០៤ ខែ មិថុនា ឆ្នាំ ២០០២ ។